ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
&&&@&&&

ក្រសួង អប់រំ យុវជន និង កីឡា
លេខ : ៤០០ អយក. ប្រក

# ប្រកាស
## ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ ត្រពាំងឈូក មកជាសាលាបឋមសិក្សាពេញលក្ខណៈ

## រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យ លេខ នស .រកត -១១៩៨- ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស - ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ នស -រកម -០១៩៦- ០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៩៨ ស្តីពី ការរៀបចំនិងការប្រព្រឹត្តរបស់ក្រសួង អប់រំ យុវជននិងកីឡា

-បានពិនិត្យលិខិតលេខ១២អយក.ខដចុះថ្ងៃទី១៣ខែកុម្ភៈឆ្នាំ២០០២របស់ការិយាល័យអប់រំ យុវជន និងកីឡាខណ្ឌដង្កោរាជធានីភ្នំពេញ

-តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋម និងមត្តេយ្យសិក្សា

## សម្រេច

ប្រការ ១ : -ផ្តាច់សាលាឧបសម្ព័ន្ធត្រពាំង ឈូក ចេញពីសាលាបឋមសិក្សា តិក្ខុបញ្ញោដែលមានទីតាំងស្ថិតនៅភូមិចែង រ៉ែម៉ង សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ មកជាសាលាបឋមសិក្សាពេញលក្ខណៈចាប់ពី ឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

ប្រការ ២ : -សាលាបឋមសិក្សា ត្រពាំង ឈូកត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗស្របតាមបទដ្ឋាន ប្រើប្រាស់ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

ប្រការ ៣ : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច តាមគោលការណ៍ កំនត់របស់រដ្ឋ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និងមត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ ការិយាល័យអប់រំ យុវជន និងកីឡា ខណ្ឌ ដង្កោ នាយកសាលាបឋមសិក្សា ត្រពាំង ឈូក នាយកសាលាបឋមសិក្សា តិក្ខុបញ្ញោមានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ . ថ្ងៃទី២៧ខែ ឧសភា ឆ្នាំ ២០០២
រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា

**អ៊ឹម_សិទ្ធី**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-ក្រសួងផែនការ
-ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
"ដើម្បីជូនជ្រាបជាពត៌មាន"
-សាលា ក្រុង ភ្នំពេញ "ជូនជ្រាបជាពត៌មាន"
-ដូចប្រការ ៥
-កាលប្បវត្តិ -ឯកសារ នា-បម